ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# កោះស័ក្តសិទ្ធិ
# សម្រាប់រយៈពេល ៣ ឆ្នាំ
# (កក្កដា ២០១៩ - មិថុនា ២០២២)

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | កោះស័ក្តសិទ្ធិ |
| ភូមិ | ៖ | កោះថ្កៅ |
| ឃុំ | ៖ | កំពង់ចាម |
| ស្រុក | ៖ | សំបូរ |
| ខេត្ត | ៖ | ក្រចេះ |

ខែមករា ឆ្នាំ២០១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# កោះស័ក្តសិទ្ធិ
# សម្រាប់រយៈពេល ៣ ឆ្នាំ
# ( កក្កដា ២០១៩ - មិថុនា ២០២២ )

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | កោះស័ក្តសិទ្ធិ |
| ភូមិ | ៖ | កោះផ្តៅ |
| ឃុំ | ៖ | កំពង់ចាម |
| ស្រុក | ៖ | សំបូរ |
| ខេត្ត | ៖ | ក្រចេះ |

ខែមករា ឆ្នាំ២០១៩

# មាតិកា


១. ស្ថានភាពទូទៅ ..... ១

២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម ..... ២

ក. ប្រជាពលរដ្ឋ ..... ២

ខ. មុខរបរ ..... ២

៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ ..... ២

ក. ទីតាំង ..... ២

ខ. ដែននេសាទ ..... ៣

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ..... ៣

ឃ. ធនធានជលផល ..... ៣

៤. ការធ្វើនេសាទ ..... ៤

ក. អ្នកនេសាទ ..... ៤

ខ. ឧបករណ៍នេសាទ ..... ៤

គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ..... ៥

៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ..... ៥

ក. ទស្សនៈវិស័យ ..... ៥

ខ. គោលបំណងរួម ..... ៥

គ. គោលបំណងជាក់លាក់ ..... ៥

ឃ. ផែនការសកម្មភាពគ្រប់គ្រងកន្លែងនេសាទសហគមន៍ ..... ៥

ឃ.១. ធនធានជលផល និងអេកូឡូស៊ី ..... ៥

ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ ..... ៧

ឃ.៣. ការគ្រប់គ្រង ..... ១០

ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ..... ១២

ច. យុទ្ធសាស្ត្រ ..... ១៣

តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ភូមិខ្សាច់លាវរយៈពេល ៣ ឆ្នាំ (២០១៩-២០២២) ..... ១៤

តារាងកម្មវិធីការងារប្រចាំឆ្នាំ (កក្កដា ២០១៩ - មិថុនា ២០២២) ..... ២៨

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១. ស្ថានភាពទូទៅ

សហគមន៍នេសាទកោះស័ក្តសិទ្ធិ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៨ ដោយខណ្ឌរដ្ឋបាលជលផលក្រចេះ និងគាំទ្រដោយអង្គការ CAA/Oxfam Australia បន្ទាប់ពីបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទឡើងវិញ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១១ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍រវាងនាយខណ្ឌរដ្ឋបាលជលផលក្រចេះ និងប្រធានគណៈកម្មការសហគមន៍នេសាទ អាណត្តិលើកទី១ នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១២ និងបានចុះកិច្ចព្រមព្រៀងលើកទី២នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ដែលរៀបចំឡើងដោយខណ្ឌរដ្ឋបាលជលផលក្រចេះ និងគាំទ្រថវិកាដោយអង្គការមូលនិធិសកលសម្រាប់អភិរក្សធនធានធម្មជាតិ (WWF)។ សហគមន៍នេសាទនេះ ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយប្រកាសលេខ១៤០ ប្រក.កសក ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៣ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ យោងតាមភាពចាំបាច់ និងអាណត្តិរបស់គណៈកម្មការសហគមន៍នេសាទ គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ (ដំណាក់កាលទី៣) សមាសភាគទី១ ដែលអនុវត្តដោយខណ្ឌរដ្ឋបាលជលផលក្រចេះ បានសម្របសម្រួលចុះធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៨។ ឆ្លងតាមការធ្វើបច្ចុប្បន្នភាព សមាជិកដែលបានចុះក្នុងបញ្ជីជាផ្លូវការ សរុបចំនួន១៣៨នាក់ ស្រីមានចំនួន៧៧នាក់។ ដោយសារផុតអាណត្តិ និងតបតាមការស្នើសុំរបស់សមាជិក សហគមន៍នេសាទនេះ បានរៀបចំបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទឡើងវិញនៅថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០១៨។ គណៈកម្មការសហគមន៍នេសាទកោះស័ក្តសិទ្ធិ ដែលទើបជាប់ឆ្នោតថ្មីមានចំនួន៩នាក់ ក្នុងនោះស្រីចំនួន២នាក់ ដោយបានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និងបែងចែកតួនាទីនិងភារកិច្ចទទួលខុសត្រូវតាមការស្ម័គ្រចិត្ត និងការឯកភាពគ្នាក្នុងចំណោមសមាជិកគណៈកម្មការទាំងអស់។ ក្រៅពីនោះ សហគមន៍ក៏បានរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍តាមរយៈកិច្ចប្រជុំថ្ងៃទី១២-១៣ ខែធ្នូ ឆ្នាំ២០១៨ និងមហាសន្និបាតអនុម័តផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានដូចខាងលើ សហគមន៍នេសាទនេះនៅមានការជួបប្រទះនូវបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី ជីវភាពប្រជាពលរដ្ឋ និងការគ្រប់គ្រងមានដូចខាងក្រោម៖

- បញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី រួមមានការបាត់បង់ពូជត្រីធំៗ អន្លង់អភិរក្សកាន់តែរាក់ ទឹកទន្លេកើតស្លែច្រើនធ្វើឱ្យត្រីពុល ដាច់បាក់ដីច្រាំងទន្លេនិងតាមកោះ ព្រៃលិចទឹកងាប់ដោយសារការកាប់រាន ទឹកមានស្លែច្រើន

- បញ្ហាប្រឈមពាក់ព័ន្ធនឹងជីវភាពប្រជាពលរដ្ឋ រួមមានចំនួនប្រជាពលរដ្ឋក្នុងឃុំកើនឡើង ប្រជាពលរដ្ឋគ្មានមុខរបរនិងការងារធ្វើ ភ្ញៀវទេសចរណ៍មកលេងកោះថយចុះ ដីមិនជាប់ទឹកដែលមិនអាចចិញ្ចឹមត្រីបាន ខ្វះបច្ចេកទេសដាំដំណាំ ចិញ្ចឹមសត្វ និងខ្វះទុនប្រកបមុខរបរ ប្រជាពលរដ្ឋមានប្រាក់ចំណូលទាប និងទីផ្សារនៅឆ្ងាយពីភូមិ

- បញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រង រួមមានបទល្មើសនេសាទមានកាន់តែច្រើនដូចជាឆក់ត្រី ដាក់មងក្រឡាធំវាយមងជាក្រុម វាយសន្ទូចប្រើនុយអប់ និងនេសាទត្រីនៅរដូវត្រីពង សមាជិកសហគមន៍នេសាទក៏នៅពុំទាន់មានការយល់ដឹង និងចូលរួមការងារសហគមន៍នេសាទឱ្យបានសស្រាក់សស្រាំ នៅមានបទល្មើសនេសាទអ្នកមកពីខាងក្រៅសហគមន៍នេសាទដោយលួចធ្វើនេសាទនៅកន្លែងអភិរក្សជាពិសេសនៅពេលយប់ សហគមន៍នេសាទចុះល្បាតមិនទៀងទាត់ដោយសារខ្វះទូក ប្រេង និងឧបករណ៍សម្ភារសម្រាប់ល្បាត មិនទាន់មានទីស្នាក់ការសហគមន៍សម្រាប់ប្រតិបត្តិការណ៍កម្មការ

សហគមន៍នេសាទពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការដឹកនាំ សហគមន៍នៅតែគិតថាការងារ គណៈកម្មការជាការងារបច្ចេកទេស និងជាតួនាទីរបស់បុរស ម្យ៉ាងទៀតសមាជិកសហគមន៍នេសាទពួកគាត់គិតថាការ ងារគ្រប់គ្រងធនធានជលផលក្នុងសហគមន៍នេសាទជាការងាររបស់គណៈកម្មការ។ ចំណែកស្ត្រីមានតួនាទីជាអ្នកថែទាំគ្រួសារ ការងារផ្ទះ លក់ដូរ និងការចូលរួមរបស់ស្ត្រីក្នុងកិច្ចប្រជុំនានាមានចំនួនច្រើនតែការសម្រេចចិត្តនៅមានកម្រិត។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក. ប្រជាពលរដ្ឋ

ចំនួនប្រជាពលរដ្ឋសរុបនៅក្នុងសហគមន៍មាន ៨២២ នាក់ ប្រុសចំនួន ៤០៦ នាក់ ស្រី ៤១៦ នាក់។ ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទជាអ្នកកាន់សាសនាព្រះពុទ្ធ ១០០ %។

ស្ថានភាពប្រជាពលរដ្ឋសរុបក្នុងតំបន់សហគមន៍ មានដូចខាងក្រោម៖

- ចំនួនស្ត្រីមេម៉ាយមាន ២៨ នាក់
- ចំនួនជនពិការមាន ១៥ នាក់ ស្រី ៧ នាក់
- ចំនួនចាស់ជរាមាន ១៩ នាក់ ស្រី ១២ នាក់
- ចំនួនកុមារកំព្រាមាន ១៨ នាក់ ស្រី ២ នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃមាន ២២ នាក់ ស្រី ១៦ នាក់
- កម្រិតសិក្សាអប់រំរួមមានអ្នកមិនចេះអក្សរមានចំនួន ៩៣ នាក់ ស្រី ៦១ នាក់ ថ្នាក់បឋមសិក្សាចំនួន ១៨៧ នាក់ ស្រី ៩៤ នាក់ កម្រិតមធ្យមសិក្សាចំនួន ៤៩ នាក់ ស្រី ២៧ នាក់ និងកម្រិតថ្នាក់ឧត្តមសិក្សាចំនួន ៧ នាក់ ស្រី ១ នាក់។

### ខ. មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន ៖

- ធ្វើនេសាទជាលក្ខណៈគ្រួសារចំនួន ១៤០ គ្រួសារ (៣០ %)
- ធ្វើស្រែវស្សាចំនួន ១៦៣ គ្រួសារ ទំហំ ១១៤,១០ ហិកតា (៧០%)
- ដាំបន្លែចំនួន ១៥ គ្រួសារ
- ធ្វើចំការចំនួន ១៥ គ្រួសារ
- ធ្វើជាងផ្ទះចំនួន ៣ គ្រួសារ
- សិប្បកម្មមូក កញ្ជើ កញ្ច្រែង ល្អីចំនួន ៣ គ្រួសារ
- លក់ដូរចាប់ហួយចំនួន ១១ គ្រួសារ។

## ៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ

### ក. ទីតាំង

កន្លែងនេសាទសហគមន៍កោះស័ក្តសិទ្ធិជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។ កន្លែងនេសាទសហគមន៍កោះស័ក្តសិទ្ធិស្ថិតនៅតាមដងទន្លេមេគង្គ មានទំហំ ៣២៩,១៥ ហិកតា និងមាននិយាមការដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់ ៖

- ខាងជើងទល់នឹងកន្លែងនេសាទសហគមន៍អន្លង់កំពង់ក្របីត្រីប៉ាសេអ៊ី
- ខាងត្បូងទល់នឹងកន្លែងនេសាទសហគមន៍វាលខ្សង
- ខាងកើតទល់នឹងភូមិកោះផ្ដៅ ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ
- ខាងលិចទល់នឹងកន្លែងនេសាទសហគមន៍ទន្សោងធ្លាក់ និងភូមិកោះពៃង ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ។

ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍កោះស័ក្ដសិទ្ធិ ស្ថិតនៅតាមដងទន្លេមេគង្គ មានកោះ និងព្រៃលិចទឹកដុះរាយនៅតាមមាត់ច្រាំងទន្លេ។ កន្លែងនេសាទសហគមន៍កោះស័ក្ដិសិទ្ធិ មានអន្លង់ចំនួន២ អូរចំនួន៤ និងកោះចំនួន២ គឺ៖

| | | |
|---|---|---|
| - អន្លង់កោះផ្ដៅធំ | ទំហំ ២៥ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - អន្លង់កោះផ្ដៅតូច | ទំហំ ១៧ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - អូរយាយឡាច | ប្រវែង ៣០០ ម៉ែត្រ | មានទឹកពីខែសីហា ដល់ តុលា |
| - អូរមានជប់ | ប្រវែង ៣០០ ម៉ែត្រ | មានទឹកពីខែកញ្ញា ដល់ តុលា |
| - អូរតាកេត | ប្រវែង ៥០០ ម៉ែត្រ | មានទឹកពីខែសីហា ដល់ វិច្ឆិកា |
| - អូរព្រៃកខ្មោច | ប្រវែង ៥០០ ម៉ែត្រ | មានទឹកពីខែសីហា ដល់ វិច្ឆិកា |
| - កោះធំ | ទំហំ ០,១២ ហិកតា | |
| - កោះតូច | ទំហំ ០,២០ ហិកតា។ | |

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

អន្លង់កោះផ្ដៅតូច ទំហំ ១៧ ហិកតា និង អន្លង់កោះផ្ដៅធំ ទំហំ ២៥ ហិកតា ជាតំបន់ដែលមានសក្ដានុពលសម្រាប់អភិរក្សត្រីមេពូជ តាមការសម្រេចរបស់មហាសន្និបាត។

ឃ. ធនធានជលផល

ឃ.១. ប្រភេទត្រី ៖

ត្រីខ្យា ត្រីឆ្លាំង ត្រីទ្រនេល ត្រីឆ្ពោក ត្រីគ្រសក់ ត្រីក្អែក ត្រីក្ដី ត្រីក្រាយ ត្រីឆ្ដោរ ត្រីរ៉ស់ ត្រីអំបូង ត្រីសណ្ដាយ ត្រីក្លាំងហាយ ត្រីប្រា ត្រីកែស ត្រីប្រាកណ្ដុរ ត្រីពោធិ៍ ត្រីព្រលូង ត្រីប៉ាវ៉ា ត្រីដំរី ត្រីប៉ាស៊ីអី ត្រីផ្ទក់ ត្រីឆ្លូញ ត្រីខ្ទឹង ត្រីរៀល ត្រីក្រឡង់ ត្រីកញ្ចុះ ត្រីគ្រុំ ត្រីក្រាញ់ ត្រីកន្ធ្រប់ ត្រីចេក ត្រីសារិកាកែវ ត្រីឆ្អិន ត្រីកាហែ ត្រីប្រកែង ត្រីចង្វារ ត្រីអណ្ដែង ត្រីស្លឹកឫស្សី ត្រីកំភ្លាវ ត្រីតាអោន ត្រីគល់រាំង ត្រីបបែល ត្រីលលកស ត្រីស្នក់ ត្រីខ្មាន់ ត្រីកាទឹម ត្រីក្រុស ត្រីកញ្ជ្រូក ត្រីអាចម៍កុក ត្រីកំបុតច្រមុះ ត្រីកញ្ជនជ័យ ត្រីក្របី ត្រីកៃ ត្រីឈ្មៀត ត្រីកំពត ត្រីផ្ទោង ត្រីអន្ទង់ ត្រីខ្លា ត្រីប្រម៉ា ត្រីរាហ៊ូ ត្រីអណ្ដាតឆ្កែ ត្រីស្លាត ត្រីននោងល្ងឹង ត្រីកន្ត្រងប្រេង ត្រីរមាស ត្រីតាយ៉ូ។

ឃ.២. ប្រភេទវារីសត្វ ៖

អណ្ដើក កន្ធាយ ល្មិច និង ពស់ អន្ទង់ និងសត្វផ្សោត។

ឃ.៣. ព្រៃលិចទឹក និងរុក្ខជាតិ

ដើមរៃ ដើមអណ្តែង ដើមអញ្ចែង ដើមអញ្ចេ ដើមទន្លា ដើមត្រស់ ដើមរាំង ដើមក្តុល ដើមផ្តៅ ដើមត្រែង ដើមស្លត និងដើមបបុស។

## ៤. ការធ្វើនេសាទ

ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ១៣៧ នាក់ ស្រី ៧៧ នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទក្នុងសហគមន៍មានចំនួន ៤២០ នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍ចំនួន ៣០ នាក់ ស្រី ១០ នាក់។

ខ. ឧបករណ៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | | | ទំហំ ប្រវែង | | | រដូវប្រើប្រាស់ឧបករណ៍នេសាទ |
|---|---|---|---|---|---|---|---|---|
| | | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | |
| សំណាញ់ | វង់ | ២០ | ១០ | ៣០ | ប្រវែង៦ម ក្រឡា១.៦ | ប្រវែង៦ម ក្រឡា១.៦ | ប្រវែង៦ម ក្រឡា១.៦ | មករា-ធ្នូ |
| បង្កៃ | ផ្លែ | ២០០ | ២០០ | ២០០ | ផ្លែលេខ៥-៦ | ផ្លែលេខ ៥-៦ | ផ្លែលេខ៥-៦ | មិថុនា-ធ្នូ |
| សន្ទូចរនង | សាង (១០០ផ្លែ) | ៣០ | | ២០ | ផ្លែលេខ ៩-១២ | | ផ្លែលេខ ៩-១២ | មករា-ធ្នូ |
| លប | គ្រឿង | ២០០ | ២១០ | ២០ | មុខ១ម បណ្តោយ២ម | មុខ១ម បណ្តោយ២ម | មុខ១ម បណ្តោយ២ម | មិថុនា-ធ្នូ |
| ចាន់ | គ្រឿង | ៣០ | ៩០ | | មុខ០,៤ម បណ្តោយ ១,៥ម | មុខ០,៤ម បណ្តោយ ១,៥ម | | មិថុនា-ធ្នូ |

ម=ម៉ែត្រ ស.ម=សង្ទីម៉ែត្រ

ប្រភេទទូកកាណូត

| ប្រភេទទូកកាណូត | ចំនួន | | | ចំណុះ | | | កម្លាំងសេះ | | |
|---|---|---|---|---|---|---|---|---|---|
| | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ |
| ទូកចែវ/អុំ | | ៥ ទូក | | | ៣០០គក្រ | | | | |
| ទូកមានម៉ាស៊ីន | ៥១ ទូក | ៣០ ទូក | ២០ ទូក | ៣០០គក្រ | ៣០០គក្រ | ៣០០ គក្រ | ៥-១៨ សេះ | ៥-១៨ សេះ | ៥-១៨ សេះ |

គ.ក្រ=គីឡូក្រាម

គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមក្នុង១គ្រួសារ (គីឡូក្រាម) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៣៧៩,៣០ | ៥៨៦,៨៦ | ៩១៦,១៦ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ក.ទស្សនៈវិស័យ

សហគមន៍នេសាទ កោះស័ក្តសិទ្ធិ មានទស្សនវិស័យរួមចំណែកគ្រប់គ្រងធនធានជលផលប្រកប ដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

ខ. គោលបំណងរួម

ដើម្បីសម្រេចបាននូវទស្សនវិស័យខាងលើ សហគមន៍នេសាទ មានគោលបំណងរួមដូចខាងក្រោម៖

- ធ្វើឱ្យត្រីមានការកើនឡើង
- បង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍នេសាទ
- បទល្មើសនេសាទមានការថយចុះ។

គ. គោលបំណងជាក់លាក់

- ការពារ និងដាំព្រៃលិចទឹកជាជម្រកត្រីនៅតាមច្រាំងទន្លេ
- បង្កើនជម្រើសមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ តាមរយៈការចិញ្ចឹមសត្វ ត្រី ដាំបន្លែ អេកូទេសចរ និងមានទីផ្សារសម្រាប់កសិផល
- កាត់បន្ថយបទល្មើសនេសាទ តាមរយៈការផ្សព្វផ្សាយ និងចុះល្បាត ដោយមានកិច្ចសហការជាមួយ អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធ។

ឃ. ផែនការសកម្មភាពគ្រប់គ្រងកន្លែងនេសាទសហគមន៍

ឃ.១. ធនធានជលផល និងអេកូឡូស៊ី

ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ត្រូវបានរៀបចំខាងក្រោម៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ការប៉ាន់ស្មានថវិកា (ដុល្លារ) |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ / ប្រវែង | ចំនួន | |
| ១. នៅតាមដងទន្លេមេគង្គនៅខាងក្រៅអន្លង់អភិ | មករា ដល់ ធ្នូ | សំណាញ់ | ប្រវែង៦ម ក្រឡា២-១៦សម | ៣០ វង់ | ១៥០(៥០/ឆ្នាំ សម្រាប់ |
| | មករា ដល់ ធ្នូ | សន្ទូចរនង(១០០ផ្លែសាង) | ផ្លែលេខ ៩-១២ | ១០០សាង | |
| | មិថុនា ដល់ ធ្នូ | លប | មុខ ១ ម ប្រវែង ២ ម | ៧០ លប | |

| | | | | | |
|---|---|---|---|---|---|
| រក្សសហគមន៍ | មិថុនា ដល់ ធ្នូ | ចាន់ | | ៥០ ចាន់ | ផ្សព្វផ្សាយ) |
| | មិថុនា ដល់ ធ្នូ | សាង ច្បូក ស្ន | | ១០ គ្រឿង | |
| | មិថុនា ដល់ ធ្នូ | ទ្រូ | | ១០ គ្រឿង | |
| | មិថុនា ដល់ ធ្នូ | ឈ្នាងត្រាំ | | ១០ គ្រឿង | |

ម=ម៉ែត្រ ស.ម=សង្ទីម៉ែត្រ

### ឃ.១.២. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍ត្រូវបានរៀបចំខាងក្រោម ៖

| ឈ្មោះ / ទីតាំង | ទំហំ (ហិតា) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| អន្លង់អភិរក្សកោះផ្តៅតូច | ១៧ | • ត្រីគ្រប់ប្រភេទ<br>• សត្វទឹកគ្រប់ប្រភេទ<br>• ព្រៃលិចទឹកគ្រប់ប្រភេទ | ដាក់ពោង និងស្លាកសញ្ញាតាមអន្លង់ | ៨០០ (៤x២០០) | កក្កដា ២០១៩ | មិថុនា ២០២២ |
| អន្លង់អភិរក្សកោះផ្តៅធំ | ២៥ | | តម្លើងផ្ទាំងផ្សព្វផ្សាយអំពីច្បាប់ជលផល និងការអភិរក្ស | ៤០០ (២x២០០) | | |
| | | | លែងកូនត្រី មេពូជ | ១.៥០០ (៣លើកx៥០០) | | |

### ឃ.១.៣. ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំខាងក្រោម ៖

| ឈ្មោះទីតាំង | ទំហំ (ហិកតា) | ប្រភេទកូនឈើដែលត្រូវដាំ និងការពារ | សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| ដាំតាមច្រាំងទន្លេ និងមាត់អូរ | ១០-៣០ម ចាប់ពីដើមមាត់អូរ ព្រែក ទន្លេ | ព្រៃលិចទឹកដែលត្រូវការពាររួមមាន៖ ត្រែង រៃ ត្រស់ រាំង ទន្លា | • ប្រជុំផ្សព្វផ្សាយពីផលប្រយោជន៍ព្រៃលិចទឹក (ស្ត្រីជាគណៈកម្មការសហគមន៍ នេសាទចូលរួមផ្សព្វផ្សាយពីផលប្រយោជន៍ព្រៃលិចទឹក ការពារព្រៃលិចទឹក និងដាក់ស្លាកសញ្ញាសម្គាល់)<br>• ការពារព្រៃលិចទឹកដែលមានស្រាប់<br>• ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹក និងស្លាកសញ្ញាសម្គាល់<br>• ដាំព្រៃលិចទឹក<br>• ចុះល្បាតជាប្រចាំ | ៣០០ (៣ឆ្នាំ) | កក្កដា ២០១៩ | មិថុនា ២០២២ |

ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ

ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល

ផែនការមុខរបរបង្កើនប្រាក់ចំណូល ត្រូវបានរៀបចំខាងក្រោម ៖

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទពូជ | បរិមាណ | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ<br>• ផ្តល់ពូជ និងទិញសម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ៤០គ្រួសារ (៥ក្បាល/គ្រួសារ) | ២.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចិញ្ចឹមទាតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមទាជាលក្ខណៈគ្រួសារ<br>• ផ្តល់ពូជ និងទិញសម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ៤០គ្រួសារ (៥ក្បាល/គ្រួសារ) | ២.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចិញ្ចឹមគោតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមគោជាលក្ខណៈគ្រួសារ<br>• ផ្តល់ពូជ និងទិញសម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ២៥គ្រួសារ (២២ក្បាល/គ្រួសារ) | ៧.៥០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចិញ្ចឹមក្របីតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមក្របីជាលក្ខណៈគ្រួសារ<br>• ផ្តល់ពូជ និងទិញសម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ២៥គ្រួសារ (២៥ក្បាល/គ្រួសារ) | ៧.៥០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាល បច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ<br>• ផ្តល់ពូជ និងទិញសម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ៥គ្រួសារ (១០ក្បាល/គ្រួសារ) | ៥០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| សួនបន្លែតាមលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលបច្ចេកទេសធ្វើសួន បន្លែជាគ្រួសារ<br>• ចែកគ្រាប់ពូជ អនុវត្តផ្ទាល់<br>• តាមដានត្រួតពិនិត្យ | បន្លែ ៥មុខ (ស្ពៃ ត្រកួន ននោង សណ្តែក កក្លួរ ត្រប់វែង) | ១០ គ្រួសារ (៥០ក្បាល/គ្រួសារ) | ៥០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| បណ្តុះផ្សិត | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត | ផ្សិតចំបើង និង | ៥ គ្រួសារ | ២៥០ | កក្កដា | មិថុនា |

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទពូជ | បរិមាណ | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|---|
| | • បណ្តុះបណ្តាលបច្ចេកទេសបណ្តុះផ្សិត និងធ្វើមេផ្សិត<br>• អនុវត្តផ្ទាល់<br>• តាមដានត្រួតពិនិត្យ | ផ្សិតអំបោះ | (៥០ក្បាល/គ្រួសារ) | | ២០១៩ | ២០២២ |
| ធ្វើមេផ្សិត | • បណ្តុះបណ្តាលបច្ចេកទេសធ្វើមេផ្សិត | ផ្សិតចំបើង និងផ្សិតអំបោះ | ១ គ្រួសារ | ៣០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចិញ្ចឹមឃ្មុំ តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាល បច្ចេកទេសចិញ្ចឹមឃ្មុំជាលក្ខណៈគ្រួសារ<br>• ផ្តល់ពូជ និងទិញសម្ភារ<br>• តាមដានត្រួតពិនិត្យ | | ១ គ្រួសារ | ៣០០ | កក្កដា ២០១៩ | មិថុនា ២០២២ |

### ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ត្រូវបានរៀបចំខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | បរិមាណ | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមត្រី អណ្តែងក្នុងអាងតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីអណ្តែងជាលក្ខណៈគ្រួសារ<br>• រៀបចំស្រះចិញ្ចឹមត្រី<br>• ផ្តល់កូនត្រី<br>• តាមដានត្រួតពិនិត្យ | ស្រះប្លាស្ទិកឬ អាងស៊ីម៉ង់ចំនួន ០១ក្នុងមួយគ្រួសារ(ទំហំ ៤មx៦មx១ម) | ១០ គ្រួសារ (៥០០/គ្រួសារ) | ៥.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |

### ឃ.២.៣. ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់

ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់ ត្រូវបានរៀបចំខាងក្រោម ៖

| ប្រភេទមុខរបរ | សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| បង្កើតក្រុមសន្សំប្រាក់ចំនួន ១ ក្រុមបន្ថែម | • ផ្សព្វផ្សាយទស្សនៈក្រុមសន្សំដល់សហគមន៍<br>• ជ្រើសរើសអ្នកទទួលផល<br>• បោះឆ្នោតជ្រើសរើសប្រធានក្រុម<br>• បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង<br>• ផ្តល់ទុនដល់ក្រុម<br>• តាមដាន និង ត្រួតពិនិត្យ | ៣០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ពង្រឹងក្រុមសន្សំប្រាក់ដែលមានស្រាប់ ១ក្រុម | • ផ្សព្វផ្សាយទស្សនៈទានក្រុមសន្សំដល់សហគមន៍<br>• ជ្រើសរើសអ្នកទទួលផលបន្ថែម<br>• ពិនិត្យកែសម្រួលគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង<br>• ផ្តល់ទុនបន្ថែមដល់ក្រុម<br>• តាមដាន និងត្រួតពិនិត្យ | ២០០ | កក្កដា ២០១៩ | មិថុនា ២០២២ |

### ឃ.២.៤. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច

ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ត្រូវបានរៀបចំខាងក្រោម ៖

| សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ជួសជុលផ្លូវលំក្នុងភូមិប្រវែង ២០០ ម៉ែត្រ | ១ ខ្សែ | ២.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ជួសជុលស្ពានឈើក្នុងភូមិព្រែកមាន់ជប់ | ១ ស្ពាន | ១០.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| សាងសង់បង្គន់អនាម័យតាមគ្រួសារបន្ថែម | ៣០ បង្គន់ | ៦.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |

### ឃ.២.៥. ផែនការពង្រឹងសកម្មភាពទេសចរណ៍ធម្មជាតិ

ផែនការពង្រឹងសកម្មភាពទេសចរណ៍ធម្មជាតិ ត្រូវបានរៀបចំខាងក្រោម ៖

| សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| រៀបចំវគ្គបណ្តុះបណ្តាលអំពីបដិសណ្ឋារកិច្ច | ៣ វគ្គ (១វគ្គ/ឆ្នាំ) | ៣០០ | មីនា ២០២០ | មីនា ២០២២ |
| តម្លើងផ្ទាំងផ្សព្វផ្សាយសកម្មភាពទេសចរណ៍ធម្មជាតិ | ១ ផ្ទាំង | ៣០០ | មីនា ២០២០ | មីនា ២០២០ |

### ឃ.៣. ការងារគ្រប់គ្រង

### ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស

ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ត្រូវបានរៀបចំខាងក្រោម ៖

| សកម្មភាព | តម្រូវការសម្ភារ | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| សហគមន៍ចុះល្បាតដោយខ្លួនឯង | | ៥ដង/១ខែ (៥ដងx១២ខែx៣x២៥) | ៤.៥០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | | ២ដង/១ខែ (២ដងx១២ខែx៣x២៥) | ១.៨០០ | | |
| ផ្តល់សម្ភារល្បាត (១ ឈុត) | អាវពោង | ១២ អាវ | ១.០០០ | | |
| | អាវភ្លៀង | ១២ អាវ | | | |
| | គោមបំភ្លឺពាក់ក្បាល | ៤ គោម | | | |
| | វិទ្យុទាក់ទង | ២ គ្រឿង | | | |
| | កែវយឺត | ២ គ្រឿង | | | |
| | ម៉ាស៊ីនថត | ១ គ្រឿង | | | |
| | អង្រឹង | ១២ | | | |
| | តង់គ្របទូក៤មx៦ម | ២ | | | |
| | សម្ភារត្រួតពិនិត្យទឹក | ១គ្រឿង | | | |
| | ស្លាបចក្រ | ៦ គ្រឿង | | | |
| | សោរជួសជុលទូក | ១សម្រាប់ | | | |
| | សោរច្រវ៉ាក់ចាក់ទូក | ២ ឈុត | | | |
| | អាវកាក់ | ១២ អាវ | | | |
| ទិញទូកស្ពាច់ និងម៉ាស៊ីន | | ២ គ្រឿង | ៣.០០០ | | |
| ប្រេងសម្រាប់ល្បាត | | ១០០ លីត្រ/ខែ (១០០លីត្រx៣៦ខែx១) | ៣.៦០០ | | |
| សេវាជួសជុលនិងថែទាំទូកនិងម៉ាស៊ីន | | ២ដង/ឆ្នាំ ៦ដងx១០០ | ៦០០ | | |
| សាងសង់ទីស្នាក់ការសហគមន៍ (ដីសាលាឆទាន) | | ១ កន្លែង | ៣.០០០ | កក្កដា ២០១៩ | កញ្ញា ២០១៩ |

### ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ

ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១ដង/១ខែ (៣៦ដងx១០) | ៣៦០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | | ៣៦០ | | |
| បណ្តុះបណ្តាលអំពីរបៀបធ្វើកំណត់ហេតុ សរសេរលិខិតរដ្ឋបាលរបាយការណ៍ និងរៀបចំទុកឯកសារ | ១លើក/១ឆ្នាំ៣ (លើកx២០) | ៦០ | | |
| បណ្តុះបណ្តាលអំពីការដោះស្រាយទំនាស់ | | ៦០ | | |
| បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | | ៦០ | | |
| បណ្តុះបណ្តាលអំពីការរៀបចំផែនការសកម្មភាពការងារ | | ៦០ | | |
| បណ្តុះបណ្តាលអំពីការកត់ត្រាចំណាយចំណូល | | ៦០ | | |
| បណ្តុះបណ្តាលអំពីការសរសេរសំណើថវិកា | ១លើក/១ឆ្នាំ (៣លើកx២០) | ៦០ | | |

### ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ

ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ ត្រូវបានរៀបចំខាងក្រោម៖

| ផែនការ | សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| បង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | ២ដង/ឆ្នាំ៣ (៦ដងx២៥) | ១៥០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| | ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍ | ១ដង/ឆ្នាំ (៣ដងx២៥) | ៧៥ | | |
| | ផ្សព្វផ្សាយដែននេសាទនិងកន្លែងអភិរក្សរបស់ សហគមន៍ | ១ដង/ឆ្នាំ៣ (១ដងx២៥) | ៧៥ | | |
| | ផ្សព្វផ្សាយពីការប្រមូលប្រាក់សមាជិកភាព និងភាគទានប្រចាំឆ្នាំ | ១ដង/ឆ្នាំ៣ (៣ដងx១០) | ៣០ | | |
| | ផ្សព្វផ្សាយច្បាប់ជលផល និងលិខិតបទដ្ឋានគតិយុទ្ធពាក់ព័ន្ធ | ១ដង/ឆ្នាំ៣ (៣ដងx២៥) | ៧៥ | | |
| | យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | ១ដង/ឆ្នាំ៣ (៣ដងx១០០) | ៣០០ | | |
| | ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរសស្ត្រីក្នុងសហគមន៍នេសាទនិងការងារផ្ទះ សមភាពនិងសមធម៌យេនឌ័រ | ១ដង/ឆ្នាំ៣ (៣ដងx២៥) | ៧៥ | | |

### ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | ១៥០ (៣លើកx៥០) | កក្កដា ២០១៩ | មិថុនា ២០២២ | គណៈកម្មការសហគមន៍នេសាទ |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | ៣០ (៣លើកx១០) | | | គណៈកម្មការសហគមន៍នេសាទ |

### ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ត្រូវបានរៀបចំខាងក្រោម ៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប (ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ចុះប្រមូលប្រាក់សមាជិកភាព | កក្កដា ២០១៩ | មិថុនា ២០២២ | ៣៣,៥០ | ១.០០០ រៀល/នាក់ (១៣៤នាក់) |
| ភាគទានប្រចាំឆ្នាំ | ចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំ | | | ៥០២,៥០ | ៥.០០០រៀល/នាក់ ក្នុងមួយឆ្នាំ (១៣៤នាក់) |
| ប្រាក់ចំណូលពីប្រភពផ្សេងៗ (អំណោយពីរាជរដ្ឋាភិបាល អំណោយពីសប្បុរសជន ជំនួយពីអង្គការជាតិ និងអង្គការដៃគូ) | • ទំនាក់ទំនងជាមួយស្ថាប័នជលផល<br>•សរសេរគម្រោងស្នើសុំពីអង្គការដៃគូ | | | ៦៨.៣២៤ | សរសេរគម្រោងចំណាយ ៥០០ដុល្លារ |
| | | | សរុប | ៦៨.៨៦០ | |

### ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ | ផ្សេងៗ |
|---|---|---|---|---|
| ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | កក្កដា ២០១៩ | មិថុនា ២០២២ | គណៈកម្មការ សហគមន៍នេសាទ | ១២០ (១២ដងx១០) |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពី ស្ត្រី ជនជាតិដើមភាគតិច និងជនជាតិភាគតិច | កក្កដា ២០១៩ | មិថុនា ២០២២ | គណៈកម្មការ សហគមន៍នេសាទ | ៦០០ (៣ដងx២០០) |

ច. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការរួមមានសមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់លើផែនការណា ដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជាការធ្វើផែនការកន្លែងអភិរក្សត្រីមេពូជ ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី និងការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការដៃគូ គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗឱ្យបានជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកានិងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀរគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ
- ជ្រើសរើសស្ត្រីមេគ្រួសារ ជាសមាជិកចំនួនយ៉ាងតិច៧% ចូលរួមក្នុងសកម្មភាពទ្រទ្រង់ជីវភាពរស់នៅ
- អញ្ជើញស្ត្រីជាសមាជិកសហគមន៍នេសាទចូលរួមយ៉ាងតិច ៤០% ក្នុងការបណ្តុះបណ្តាល សិក្ខាសាលា និងសកម្មភាព ទ្រទ្រង់ជីវភាពរស់នៅ និងវារីវប្បកម្ម
- កម្មករគ្មានជំនាញជាស្ត្រីជាសមាជិកសហគមន៍នេសាទ៤០%ចូលរួមសកម្មភាពហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច
- អញ្ជើញស្ត្រីមេគ្រួសារ ស្ត្រីជនជាតិដើមភាគតិច និងជនជាតិភាគតិចជាសមាជិកសហគមន៍នេសាទ ចូលរួមប្រជុំ និងចូលរួមសកម្មភាពនានា និងចូលជាគណៈកម្មការរបស់សហគមន៍នេសាទ
- ជ្រើសរើសស្ត្រីជាសមាជិកសហគមន៍នេសាទ ៥០% ចូលរួមក្នុងសកម្មភាពគាំទ្រជីវភាព
- ផ្តល់ឱកាសស្ត្រី៥០%ជាសមាជិកសហគមន៍នេសាទចូលរួមក្នុងសកម្មភាពគាំទ្រជីវភាព និងទទួលផលប្រយោជន៍ពីគម្រោងក្នុងនោះស្ត្រីជាមេគ្រួសារ៧%
- លើកទឹកចិត្តស្ត្រីជាគណៈកម្មាការចូលរួមក្នុងការសម្រេចចិត្តនានា
- លើកទឹកចិត្តស្ត្រីជាគណៈកម្មាការមិនបោះបង់ចោលការងារ
- រៀបចំការប្រជុំឱ្យសមស្របនឹងពេលវេលារបស់ស្ត្រី ដែលមានលទ្ធភាពចូលរួម

ជំរុញឱ្យមានស្ត្រីយ៉ាងតិច២៥% ជាសមាជិកគណកម្មាការសហគមន៍នេសាទ។

## តារាងសង្ខេបផែនការគ្រប់គ្រងតំបន់នេសាទសហគមន៍កោះសំគួស៊ីធីរយៈពេល ៣ ឆ្នាំ (កក្កដា ២០១៩- មិថុនា ២០២២)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.១. ធនធានជលផល និងអេកូឡូស៊ី | | | | | | | |
| ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលា និងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់ | ផែនការប្រើប្រាស់ឧបករណ៍នេសាទត្រូវបានផ្សព្វផ្សាយ ២ដង ក្នុង០១ឆ្នាំ (រដូវបិទ និងបើកនេសាទ) | ១៥០ | រដ្ឋបាលជលផល សហគមន៍នេសាទ អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ឃ.១.២. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍ | ដាក់ពោង និងស្លាកសញ្ញាសំគាល់កន្លែងអភិរក្ស (ប្រើក្បូនឬស្សី) | ស្លាកសញ្ញាសំគាល់កន្លែងអភិរក្សចំនួន ៤ ស្លាកត្រូវបានតំឡើង | ៨០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | ធ្នូ ២០១៩ | |
| | តម្លើងផ្ទាំងផ្សព្វផ្សាយអំពីច្បាប់ជលផល និងការអភិរក្ស | ផ្ទាំងផ្សព្វផ្សាយអំពីច្បាប់ជលផលនិងការអភិរក្សចំនួន ២ផ្ទាំងត្រូវបានតំលើង | ៨០០ | | កក្កដា ២០១៩ | ធ្នូ ២០១៩ | |
| | លែងកូនត្រីពូជ | កូនត្រីពូជរួមមានៈត្រីប្រា ត្រីឆ្ពិន ត្រីឆ្ពោរ ត្រីខ្យា | ១.៥០០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ឃ.១.៣. ផែនការគ្រប់គ្រងព្រៃលិចទឹក | ដាំព្រៃលិចទឹកតាមច្រាំងទន្លេ និងមាត់អូរចាប់ពីដើមភូមិដល់ចុងភូមិ | ព្រៃលិចទឹកត្រូវការពារ ព្រមទាំងដាំឡើងវិញ ក្រែង រៃ ត្រស់ រាំង ទន្លា | ៣០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ | | | | | | | |
| ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល | ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | ៤០ គ្រួសារ | ២.០០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ចិញ្ចឹមទាតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | ៤០ គ្រួសារ | ២.០០០ | | | | |
| | ចិញ្ចឹមគោតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | ២៥ គ្រួសារ | ៧.៥០០ | | | | |
| | ចិញ្ចឹមក្របីតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | ២៥ គ្រួសារ | ៧.៥០០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | ៥ គ្រួសារ | ៥០០ | | | | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | រៀបចំសួនបន្លែតាមលក្ខណៈគ្រួសារ | ១០ គ្រួសារ | ៥០០ | | | | |
| | បណ្ដុះ ផ្សិត | ៥ គ្រួសារ | ២៥០ | | | | |
| | ធ្វើមេផ្សិត | ១ គ្រួសារ | ៣០០ | | | | |
| | ចិញ្ចឹមឃ្មុំតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | ១ គ្រួសារ | ៣០០ | | | | |
| ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | ចិញ្ចឹមត្រីអណ្ដែងក្នុងអាងតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | សមាជិកសហគមន៍១០គ្រួសារមានជំនាញ ចិញ្ចឹមត្រី និងអាចរកប្រាក់ចំណូល ធ្វើឱ្យជីវភាពប្រសើរឡើង | ៥.០០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ឃ.២.៣. ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់ | បង្កើតក្រុមសន្សំប្រាក់ចំនួន១ក្រុមបន្ថែម | ក្រុមសន្សំប្រាក់ចំនួន ១ ក្រុម ត្រូវបានបង្កើតឡើង | ៣០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ពង្រឹងក្រុមសន្សំប្រាក់ដែលមានស្រាប់ | ក្រុមសន្សំ ដែលមានស្រាប់ចំនួន១ក្រុម ត្រូវបានពង្រឹង | ២០០ | | | | |
| ឃ.២.៤. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ | ជួសជុលផ្លូវលំក្នុងភូមិ | ផ្លូវលំ១ខ្សែប្រវែង ២០០ម ត្រូវបានជួសជុល និងប្រើជាប្រយោជន៍រួមរបស់សហគមន៍ | ២.០០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ជួសជុលស្ពានឈើក្នុងភូមិ | ស្ពានឈើ ១កន្លែងត្រូវបានជួសជុលប្រើជាប្រយោជន៍រួមរបស់សហគមន៍ | ១០.០០០ | | | | |
| | សាងសង់បង្គន់អនាម័យតាមគ្រួសារបន្ថែម | ៣០ បង្គន់ | ៦.០០០ | | | | |
| ឃ.២.៥. ផែនការពង្រឹងសកម្មភាពទេសចរណ៍ធម្មជាតិ | រៀបចំវគ្គបណ្ដុះបណ្ដាលពីបដិសណ្ឋារកិច្ច | ៣ វគ្គ (១វគ្គ/ឆ្នាំ) | ៣០០ | រដ្ឋបាលជលផល អង្គការដៃគូ | មីនា ២០២០ | មីនា ២០២២ | |
| | តម្លើងផ្ទាំងផ្សព្វផ្សាយសកម្មភាពទេសចរណ៍ធម្មជាតិ | ១ ផ្ទាំង | ៣០០ | | មីនា ២០២០ | មីនា ២០២០ | |
| ឃ.៣. ការងារគ្រប់គ្រង | | | | | | | |
| ឃ.៣.១. ផែនការ | សហគមន៍ចុះល្បាតដោយខ្លួនឯង | ៥ដង/ខែ | ៤.៥០០ | រដ្ឋបាលជលផល | កក្កដា | មិថុនា | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| សកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស | ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | ២ដង/ខែ | ១.៨០០ | អង្គការដៃគូ | ២០១៩ | ២០២២ | |
| | ផ្តល់សម្ភារល្បាត | ១ ឈុត | ១.០០០ | | កក្កដា ២០១៩ | កញ្ញា ២០១៩ | |
| | ទិញទូកស្នាច់ និង ម៉ាស៊ីន | ២ គ្រឿង (១តូច ១ធំ) | ៣.០០០ | | | | |
| | ទិញប្រេងសម្រាប់ល្បាត | ១០០ លីត្រ/១ខែ | ៣.៦០០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ជួសជុលនិងថែទាំទូក និងម៉ាស៊ីន | ២ ដង/ឆ្នាំ | ៦០០ | | | | |
| | សាងសង់ទីស្នាក់ការសហគមន៍ | ស្នាក់ការចំនួន១ ត្រូវបានសាងសង់ | ៣.០០០ | | កក្កដា ២០១៩ | កញ្ញា ២០១៩ | |
| ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ | ប្រជុំប្រចាំខែគណៈកម្មការសហគមន៍នេសាទ | ១ដង/១ខែ | ៣៦០ | រដ្ឋបាលជលផល សហគមន៍នេសាទ អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | ១ដង/១ខែ | ៣៦០ | | | | |
| | បណ្តុះបណ្តាលការធ្វើកំណត់ហេតុ លិខិតរដ្ឋបាល របាយការណ៍ និងរៀបចំទុកឯកសារ | ១លើក/១ឆ្នាំ | ៦០ | | | | |
| | បណ្តុះបណ្តាលអំពីការដោះស្រាយទំនាស់ | ១លើក/១ឆ្នាំ | ៦០ | | | | |
| | បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | ១លើក/១ឆ្នាំ | ៦០ | | | | |
| | បណ្តុះបណ្តាលអំពីការរៀបចំផែនការសកម្មភាពការងារ | ១លើក/១ឆ្នាំ | ៦០ | | | | |
| | បណ្តុះបណ្តាលពីការកត់ត្រាចំណាយចំណូល | ១លើក/១ឆ្នាំ | ៦០ | | | | |
| | បណ្តុះបណ្តាលអំពីការសរសេរសំណើថវិកា | ១លើក/១ឆ្នាំ | ៦០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | ២ដង/ឆ្នាំ | ១៥០ | រដ្ឋបាលជលផល សហគមន៍នេសាទ អង្គការដៃគូ | | | |
| | ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍ | ១ដង/ឆ្នាំ | ៧៥ | | | | |
| | ផ្សព្វផ្សាយពីកន្លែងអភិរក្សសហគមន៍នេសាទ | ១ដង/ឆ្នាំ | ៧៥ | | | | |
| | ផ្សព្វផ្សាយពីការប្រមូលប្រាក់បដិភាគ | ១ដង/ឆ្នាំ | ៣០ | | | | |



th

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | ផ្សព្វផ្សាយច្បាប់ជលផល និងលិខិតបទដ្ឋានគតិយុទ្ធពាក់ព័ន្ធ | ១ដង/ឆ្នាំ | ៧៥ | | | | |
| | យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | ១ដង/ឆ្នាំ | ៣០០ | | | | |
| | ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរស ស្ត្រីក្នុងសហគមន៍នេសាទ និងការងារផ្ទះ សមភាព និងសមធម៌យេនឌ័រ | ១ដង/ឆ្នាំ | ៧៥ | | | | |
| ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | ១ដង/ឆ្នាំ | ១៥០ | រដ្ឋបាលជលផល សហគមន៍នេសាទ អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | ១ដង/ឆ្នាំ | ៣០ | គណៈកម្មការ | | | |
| ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | ភាគទានពីសមាជិកសហគមន៍នេសាទ | សមាជិកបានបង់ភាគទានសមាជិកភាព | ៣៣,៥០ | ថវិកាសហគមន៍នេសាទ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ភាគទានប្រចាំឆ្នាំ | ១ឆ្នាំម្តង | ៥០២,៥០ | | | | |
| | ប្រាក់ចំណូលពីប្រភពផ្សេងៗ (អំណោយពីរាជរដ្ឋាភិបាល អំណោយពីសប្បុរសជន ជំនួយពីអង្គការជាតិ និងអង្គការដៃគូ) | សហគមន៍នេសាទទទួលបានកញ្ចប់ថវិកាពីប្រភពផ្សេងៗ | ៦៨.៣២៤ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | ៤ដង/ឆ្នាំ | ១២០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពី ស្ត្រី ជនជាតិដើមភាគតិច និងជនជាតិភាគតិច | ១ដង/ឆ្នាំ | ៦០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |

# តារាងកម្មវិធីការងារប្រចាំឆ្នាំ ( កក្កដា ២០១៩- មិថុនា ២០២២ )

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ឃ.១. ធនធានជលផល និងអេកូឡូស៊ី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំពេលវេលា និងទីកន្លែងនេសាទ និងប្រភេទឧបករណ៍ហាមឃាត់ | | | | X | | | | | | | X | | | | | X | | | | | | | X | | | | | X | | | | | | | X | |
| ឃ.១.២. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ដាក់ពោងនិងស្លាកសញ្ញាសំគាល់កន្លែង អភិរក្ស | X | X | X | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| តម្លើងផ្ទាំងផ្សព្វផ្សាយអំពីច្បាប់ជលផល និងការអភិរក្ស | X | X | X | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| លែងកូនត្រីពូជ | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | |
| ឃ.១.៣. ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ដាំព្រៃលិចទឹកតាមប្រាំងទន្លេមាត់អូរ និងមាត់អូរចាប់ពីដើមភូមិដល់ចុងភូមិ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ឃ.២. គាំទ្រជីវភាពប្រជាពលរដ្ឋ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចិញ្ចឹមមាន់ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ចិញ្ចឹមទា | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចិញ្ចឹមគោ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចិញ្ចឹមក្របី | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចិញ្ចឹមជ្រូក | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| រៀបចំសួនបន្លែ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| បណ្តុះផ្សិត | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ធ្វើមេផ្សិត | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចិញ្ចឹមឃ្មុំតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចិញ្ចឹមត្រីអណ្តែងក្នុងអាងតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ឃ.២.៣. ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| បង្កើតក្រុមសន្សំប្រាក់បន្ថែម | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ពង្រឹងក្រុមសន្សំប្រាក់មានស្រាប់ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ឃ.២.៤. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ជួសជុលផ្លូវលំក្នុងភូមិ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ជួសជុលស្ពានឈើក្នុងភូមិ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| សាងសង់បង្គន់អនាម័យ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ឃ.២.៥. ផែនការពង្រឹងសកម្មភាពទេសចរណ៍ធម្មជាតិ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| រៀបចំវគ្គបណ្តុះបណ្តាលអំពី | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| បដិសណ្ឋារកិច្ច | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| តម្លើងផ្ទាំងផ្សព្វផ្សាយសកម្មភាពទេសចរណ៍ធម្មជាតិ | | | | | | | | | X | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.៣. ការគ្រប់គ្រង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| សហគមន៍ចុះល្បាត | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ផ្តល់សម្ភារល្បាត | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ទិញទូកស្នាច់ និងម៉ាស៊ីន | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ទីញប្រេងសម្រាប់ល្បាត | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ជួសជុលនិងថែទាំទូកនិងម៉ាស៊ីន | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| សាងសង់ទីស្នាក់ការសហគមន៍ | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| បណ្តុះបណ្តាលការធ្វើកំណត់ហេតុ លិខិតរដ្ឋបាលរបាយការណ៍ និងរៀបចំទុកឯកសារ | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X |
| បណ្តុះបណ្តាលអំពីការដោះស្រាយទំនាស់ | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| បណ្តុះបណ្តាលភាពជាអ្នកដឹកនាំ | | | | | X | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | |
| បណ្តុះបណ្តាលអំពីការរៀបចំផែនការសកម្មភាពការងារ | | | | | | X | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | |
| បណ្តុះបណ្តាលអំពីការកត់ត្រាចំណាយចំណូល | | | | | | | X | | | | | | | | | | | X | | | | | | | | | | | | X | | | | | | |
| បណ្តុះបណ្តាលអំពីការសរសេរសំណើថវិកា | | | | | | | | X | | | | | | | | | | | X | | | | | | | | | | | | X | | | | | |
| ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃ ក្នុងសហគមន៍នេសាទ | | X | | | | | | | | | X | | | X | | | | | | | | | X | | | X | | | | | | | | | X | |
| ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍នេសាទ | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | |
| ផ្សព្វផ្សាយដែននេសាទនិងកន្លែងអភិរក្សរបស់សហគមន៍ | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | |
| ផ្សព្វផ្សាយប្រមូលប្រាក់បដិភាគ | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | |
| ផ្សព្វផ្សាយច្បាប់ជលផល និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | |
| យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ប្រជុំផ្សព្វផ្សាយពីតួនាទីបុរសស្ត្រីក្នុងសហគមន៍នេសាទការងារផ្ទះ សមភាព/សមធម៌យេនឌ័រ | | | | | X | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | |
| ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍តាមរយៈបុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | X | X | | | | | | | | | | | X | X | | | | | | | | | | | X | X | | | | | | | | | | |
| ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ភាគទានពីសមាជិកសហគមន៍ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ភាគទានប្រចាំឆ្នាំ | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | |
| ប្រាក់ចំណូលពីប្រភពផ្សេងៗ (អំណោយពីរាជរដ្ឋាភិបាល អំណោយពីសប្បុរសជន ជំនួយពី អង្គការជាតិ និងអង្គការដៃគូ) | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| [illegible]. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់ | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ណៈកម្មការសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីស្ត្រី ជនជាតិដើមភាគតិច និងជនជាតិភាគតិច | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | |

លេខ : ១៧ ស.រ.ដ.ស.ឋ
បានឃើញ និងគោរពជូន
លោកនាយផ្នែករដ្ឋបាលជលផលកំពី
"ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ...............ខែ.........ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
សំបូរ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០១៩
នាយសង្កាត់រដ្ឋបាលជលផលសំបូរ

ស៊ុំ.សារ៉ាវុធ

លេខ : ០៧២/១៩
បានឃើញ និងគោរពជូន
លោកនាយសង្កាត់រដ្ឋបាលជលផលសំបូរ
"ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ...............ខែ.........ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ឃុំកំពង់ចាម ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០១៩
មេឃុំកំពង់ចាម

ឈិត_ណាន

សូមគោរពជូន
លោកមេឃុំកំពង់ចាម
"ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ...............ខែ.........ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ភូមិកោះខ្ចៅ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០១៩
ប្រធានគណៈកម្មការសហគមន៍នេសាទកោះស័ក្តិសិទ្ធ

សេង ចន្ទី

លេខ : ០៣២...ន.វ.ក.៣

បានឃើញ និងគោរពជូន

លោកនាយខណ្ឌរដ្ឋបាលជលផលក្រចេះ

"ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ............ ខែ.......ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

កាំពី ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០១៩

ជ.នាយផ្នែករដ្ឋបាលជលផលកាំពី

ទូ សុវណ្ណ

លេខ :...១៥៥...ខរ.ក្រច

បានឃើញ និងគោរពជូន

លោកប្រធាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ

"ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ............ ខែ.......ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ក្រចេះ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០១៩

នាយខណ្ឌរដ្ឋបាលជលផលក្រចេះ

**ឡៀន តិន**

លេខ :...៦២១.កសរន.ក្រច

បានឃើញ និងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

"ដើម្បីជូនពិនិត្យ និងសម្រេចដោយអនុគ្រោះ"

ថ្ងៃ............ ខែ.......ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ក្រចេះ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០១៩

ប្រធាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ

**ឡើ សុភក្តិ**

លេខ :...២១០១........

បានឃើញ និងឯកភាព

ថ្ងៃ.................... ខែ.......ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៩

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**